អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព៖** **ល្បែងហុចបាល់បន្តគ្នា**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

បំណិនចលកធំ (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំតូច និងសាច់ដុំធំ)។

**សិក្សាសង្គម**

ការយល់ដឹងពីតម្លៃមនុស្ស (កម្លាំងនិងការយល់ដឹងនិងចរិកលក្ខណៈមនុស្ស)

**ភាសាខ្មែរ**

ការយល់ដឹងពីភាសាដទៃ (ការយល់ដឹងការប្រើភាសាខុសគ្នាសម្រាប់ប្រាស្រ័យទាក់ទងគ្នាក្រៅពីភាសាផ្ទាល់ខ្លួន)

ការសន្ទនា (សន្ទនាដោយប្រើពាក្យ ឬ ឃ្លាត្រូវតាមវ័យ ភាសាបង្ហាញអារម្មណ៍ និងមនោសញ្ចេតនា)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។
បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(សិក្សាសង្គម)** ប្រាប់បានពីការគោរពចាស់ទុំ។

**(ភាសាខ្មែរ)** ប្រាប់បាននៅឈ្មោះភាសាផ្សេងៗគ្នាដែលគេកំពុងនិយាយក្រៅពីភាសាកំណើតរបស់ខ្លួន។
ប្រាប់បានព័ត៌មានផ្ទាល់ខ្លួន ឬ ព្រឹត្តិការណ៍ផ្សេងៗដែលបានជួបតាមលំដាប់លំដោយនៃសាច់រឿង។ សួរសំណួរនិងទទួលព័ត៌មានត្រលប់មកវិញ។

**រយៈពេល** ៖ ១០ ទៅ១៥ នាទី

**ឧបករណ៍** ៖ បាល់២-៣គ្រាប់(បាល់១សម្រាប់ក្មេង១០នាក់)
បទចម្រៀង និងបាសសម្រាប់ចាក់បទចម្រៀង ។

**ការរៀបចំ** ៖ រៀបចំសំណួរ។ ឧទាំហរណ៍…
១.សួស្តី តើអ្នកសុខសប្បាយដែរឬទេ? - បាទ ខ្ញុំសុខសប្បាយទេ។
២.សួស្តី! តើអ្នកឈ្មោះអ្វីដែរ? - បាទ ខ្ញុំឈ្មោះ….
៣.ជម្រាបលា! ជួបគ្នាពេលក្រោយ! - ជម្រាបលា! ជួបគ្នាពេលក្រោយ!
(រីករាយដែលបានស្គាល់អ្នក ប្រសិនបើមាន)

**សេចក្តីណែនាំ៖**

1. និយាយថា៖ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងហុចបាល់បន្តគ្នា**។
2. ឱ្យក្មេងឈរជារង្វង់ចំណែកអ្នកគ្រូត្រូវឈរនៅខាងក្នុងរង្វង់។
3. អ្នកគ្រូត្រូវចាំត្រៀមចាក់បទភ្លេង ដើម្បីចាំមើល តើនរណាជាអ្នកទទួលបាល់ចុងក្រោយ?។

4. ជ្រើសរើសក្មេងម្នាក់កាន់បាល់ដំបូងរួចហុចឱ្យអ្នកបន្ទាប់ពីម្នាក់ទៅម្នាក់ទៀតបន្តគ្នាឱ្យជុំវិញរង្វង់ រហូតអ្នកគ្រូបិទបទភ្លេង។
5. ឯអ្នកទទួលបាល់ចុងក្រោយបន្ទាប់ពីបិទបទភ្លេងនឹងត្រូវសន្ទនាជួបគ្នាដំបូង។
   តើអ្នកសុខសប្បាយដែរឬទេ?
   តើកូនហូបបាយនៅ?
   តើកូនបានដុសធ្មេញមុនមកសាលារៀននៅ?
   តើកូនបានជម្រាបលាម៉ាក់ប៉ាមុនមករៀននៅ?
   តើកូនឈ្មោះអ្វី? អាយុប៉ុន្មាន?
   និងសំណួរអ្វីក៏បានដែរ ឱ្យតែទាក់ទងទៅនឹងសាលារៀន
   មិត្តភក្តិឬឪពុកម្តាយរបស់ពួកគេជាការស្រេច…។
6. ត្រូវរង់ចាំក្មេងឆ្លើយជាមួយនឹងអ្នក តែប្រសិនបើក្មេងមិនសូវចេះ យើងអាចជួយប្រាប់បាន ។
7. ចាប់ផ្តើមចាក់តន្ត្រីម្តងទៀតនិងឱ្យក្មេងៗហុចបាល់ជុំវិញម្តងទៀត សម្រាប់បទចម្រៀង អ្នកអាចជ្រើសរើសយកបទអ្វីក៏បានដែរ សំខាន់ឱ្យតែទាក់ទងទៅនឹងបទរបស់កុមារ។
8. បើក្មេងដែលទទួលបានបាល់ធ្លាប់បានសន្ទនាជួបគ្នាដំបូងរួចហើយ សូមផ្លាស់ប្តូរទៅឱ្យក្មេងផ្សេងដែលមិនទាន់បានឆ្លើយ។
9. លេងបែបនេះរហូតក្មេងៗបានឆ្លើយទាំងអស់គ្នា។






**ការប្រែប្រួលៈ**

ផ្លាស់ប្តូរលេងល្បែងនេះទៅតាមប្រធានបទផ្សេងទៀតទៅតាមអ្វីដែលក្មេងៗបានរៀនពីមុនមកបានតាមសប្បាយ ។